## ៦. ផែនការគ្រប់គ្រងបរិស្ថាន តម្រូវការស្ថាប័ន និងការពិនិត្យ-តាមដាន-វាយតំលៃបរិស្ថាន

**២០៣.** យោងតាមវិធានការណ៍គ្រប់គ្រង ដូចមាននៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថានសំរាប់គំរោងអភិវឌ្ឍន៏ដំណាំកសិឧស្សាហកម្មគឺដំណាំពោត និងដំណាំផ្សេងៗ ម្ចាស់គំរោងជាអ្នកទទួលខុសត្រូវសំខាន់ក្នុងការគ្រប់គ្រងបរិស្ថានរបស់គំរោងនេះ ចំណែកឯក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ (ក្រុមការងារបច្ចេកទេសរបស់លេខាធិការដ្ឋានដីសម្បទានសេដ្ឋកិច្ច) អាជ្ញាធរ ជាអ្នកតាមដានពិនិត្យ និងវាយតំលៃការអនុវត្តន៏របស់ម្ចាស់គំរោងដោយផ្ទាល់ ។

**២០៤.** យោងលើលទ្ធផលនៃការអង្កេតនៅលើទីវាល និងការប្រមូលទិន្នន័យក្នុងរយៈពេលនៃការសិក្សាស៊ីជម្រៅបានបង្ហាញថា គំរោងអភិវឌ្ឍន៏ដំណាំកសិឧស្សាហកម្មនេះមិនតម្រូវអោយមានការចូលរួមពីស្ថាប័ន និងការត្រួតពិនិត្យបរិស្ថានច្រើនប៉ុន្មានទេ ដោយសារថាហេតុប៉ះពាល់អវិជ្ជមានមានតិចតួច ។ ក្រៅពីអ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator) និងស្ថាប័នជំនាញ (មានក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) គម្រោងនេះមិនចាំបាច់តម្រូវអោយមានស្ថាប័នត្រួតពិនិត្យឯករាជ្យ (Independent Monitoring Organization) ដើម្បីត្រួតពិនិត្យការអនុវត្តន៏ទេ ។ ប៉ុន្តែក្រុមហ៊ុន **អេចអិលអេច អេហ្គ្រីខលឈ័រ (ខេមបូឌា)ខូអិលធីឌី** ខ្លួនឯងមានតួនាទីទទួលខុសត្រូវស្នូលក្នុងការគ្រប់គ្រងបរិស្ថានរបស់ គំរោងដោយ ផ្អែកលើវិធានការណ៍គ្រប់គ្រងបរិស្ថានដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រង បរិស្ថានរបស់របាយការណ៍ SEIA ។ ក្នុងបរិបទនេះដើម្បីធានាបានថាក្រុមហ៊ុន **អេច អិល អេច អេហ្គ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** ប្រតិបត្តិតាម វិធានការណ៍នៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម ដូចមានបង្ហាញនៅក្នុង តារាងទី ៦-១ និង៦-៣ បានត្រឹមត្រូវនោះក្រសួងបរិស្ថាន (នាយកដ្ឋាន EIA) និងក្រុមការងារចំរុះរបស់ លេខាធិការដ្ឋានបច្ចេកទេស ដីសម្បទានសេដ្ឋកិច្ចដែលមានស្នាក់ការនៅក្រសួងកសិកម្ម ត្រូវចុះតាមដានពិនិត្យ និងវាយតំលៃដំណើរប្រតិបត្តិ របស់ក្រុមហ៊ុនទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងតារាង៦-៣ដោយផ្ទាល់ ។

**២០៥.** ដើម្បីធានាបានថា វិនិយោគិននឹងទទួលបាននូវផ្ទៃដីចំនួន ៩៩៨៥ហិកតា សម្រាប់បែងចែកការប្រើប្រាស់ទៅតាមមុខងារនៃការប្រើប្រាស់ដីដូចមានកំណត់នៅក្នុងចំណុច (២-៦-៤-៦ ផែនការបែងចែក និងរៀបចំដីដាំដុះ) មែននោះ ក្រោយពីរាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍អោយក្រុមហ៊ុនធ្វើការវិនិយោគហើយក្រុមហ៊ុនគួរត្រូវសហការជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ និងជំលោះដីធ្លី ដើម្បីធ្វើការបញ្ជាក់ថាផ្ទៃដីខាងលើពិតជាដីសាធារណៈរបស់រដ្ឋទាំងស្រុង មិនជាប់ជំពាក់ជាមួយនឹងការប្រើប្រាស់ដី ជាពិសេសពីសំណាក់ឈ្មួញកណ្តាលឱកាសនិយម ធ្វើពាណិជ្ជកម្មដើម្បីប្រយោជន៏ផ្ទាល់ខ្លួន ដោយលើកលែងតែម្ចាស់ដើមមួយចំនួន

Draft

តូចដែលកាន់កាប់នឹងប្រើប្រាស់ដីតំបន់នោះតាំងពីមុនមក ដែលតម្រូវអោយមានការដោះស្រាយតាមបែបគោលនយោបាយ។

**២០៦.** ក្រោយពីកំណត់អត្តសញ្ញាណនៃការប្រើប្រាស់ដីហើយ និងបានដោះស្រាយជាមួយប្រជាពលរដ្ឋ ចប់សព្វគ្រប់រួច ក្រុមហ៊ុនត្រូវសហការជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គណៈកម្មការ បច្ចេកទេសដីសម្បទានសេដ្ឋកិច្ច) ដើម្បីចុះទៅធ្វើការកំណត់ព្រំប្រទល់ជាបន្ទាន់ទៅតាមទំហំ និងទីតាំងនិយាមកា ដូចមានបែងចែកនឹងកំណត់យ៉ាងពិស្តារនៅក្នុងតារាង៣-១ មុននឹងឈានទៅរៀបចំផែនការប្រតិបត្តិផ្សេងៗ។

**២០៧.** អ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator - LEC) នឹងត្រូវតាមដានត្រួតពិនិត្យនូវហេតុប៉ះពាល់ នៅក្នុងអាយុកាលនៃការប្រតិបត្តិគំរោង ដើម្បីធានាបានថាដំណើរប្រតិបត្តិនេះ បានអនុវត្តទៅតាមល័ក្ខខ័ណ្ឌរបស់ផែនការគ្រប់គ្រងបរិស្ថាន។ ម្ចាស់គំរោងមិនត្រូវចាប់ផ្តើមដំណើរការគំរោងមុនពេលដែលក្រសួងបរិស្ថានផ្តល់ការអនុម័តជាផ្លូវការឡើយ។

**២០៨.** ការតាមដានត្រួតពិនិត្យវាយតំលៃគំរោង ត្រូវធ្វើទៅតាមតម្រូវការនៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដូចបានសង្ខេបនៅក្នុងតារាង៦-៣។ ម្ចាស់គំរោងត្រូវធ្វើសាវនកម្មផ្ទៃក្នុងរៀងរាល់១ខែម្តងទៅលើការអនុវត្តន៏ EMP លើដំណើរការប្រតិបត្តិទាំងមូល ក្នុងពេលដែលស្ថាប័នជំនាញ ត្រូវធ្វើសាវនកម្មទៅលើការអនុវត្តន៏ EMP លើដំណើរការរបស់ប្រតិបត្តិការទាំងមូលរៀងរាល់៣ខែម្តង។ ការធ្វើសាវនកម្មនេះចាំបាច់ត្រូវមានការចូលរួមពីគណៈកម្មការអន្តរក្រសួង មន្ត្រីសមត្ថកិច្ចស្រុក និងខេត្ត ដែលអាចកំណត់អំពីកំហុសឆ្គងណាមួយនឹងផ្តល់សេចក្តីកែតម្រូវតាមការចាំបាច់។ ស្ថាប័នជំនាញ មានតួនាទីទទួលខុសត្រូវក្នុងការពិនិត្យលើនីតិវិធីប្តឹងតវ៉ាដើម្បីធានាបានថា ការផ្តល់ប្រាក់ឧបត្ថម្ភចំពោះបុគ្គលិក/កម្មករដែលរងគ្រោះទទួលការដោះស្រាយបានត្រឹមត្រូវពីម្ចាស់ក្រុមហ៊ុនឬមួយយ៉ាងណា ហើយរាយការណ៍ទៅក្រសួងបរិស្ថានតាមរយៈអ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន។

**២០៩.** ម្ចាស់ក្រុមហ៊ុនត្រូវធ្វើការបណ្តុះបណ្តាលអំពីបទដ្ឋាននៃការគ្រប់គ្រងបរិស្ថាន គោលនយោបាយផែនការនិងនីតិវិធីនៃការអនុវត្តន៏និងការត្រួតពិនិត្យតាមដានដំណើរប្រតិបត្តិការគំរោងដល់បុគ្គលិករបស់ខ្លួន និងឬក៏អ្នកម៉ៅការបន្ត។ អ្នកជំនាញបរិស្ថានត្រូវរៀបចំសៀវភៅប្រតិបត្តិសង្ខេបដល់អ្នកសម្របសម្រួបបរិស្ថាននៅមូលដ្ឋាន ហើយត្រូវត្រួតពិនិត្យវាយតំលៃ និងផ្តល់នូវមតិយោបល់ផ្សេងៗដល់ម្ចាស់ក្រុមហ៊ុន ថាតើអ្នកបច្ចេកទេសបរិស្ថានរបស់ក្រុមហ៊ុនគួរមានសមត្ថភាពកំរិតណាដើម្បីធានាបានដល់ការអនុវត្តន៏ និងការគ្រប់គ្រងការងារទាំងអស់នោះ។

Draft

## តារាង៦-១: វិធានការសង្ខេបកាត់បន្ថយហេតុប៉ះពាល់

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង** | | | | |
| **ការធ្វើផែនការ** | សុខភាពការងារ និងផែនការសុវត្ថិភាព | (១) **ការការពារជំងឺគ្រុនចាញ់:** ប្រសិនបើគ្មានការគ្រប់គ្រងកន្លែងដែលមូសរស់នៅអោយបានជិតដល់ទេអាចនឹងធ្វើអោយកើតជំងឺគ្រុនចាញ់បាន។ អនុសាសន៍សំខាន់ៗសំរាប់ការការពារនិងការកាត់បន្ថយនូវការកើតជំងឺមានដូចជា: (១) ការស្វែងរកឱ្យបានទាន់ពេលវេលាតាមរយៈការពិនិត្យលើលក្ខណៈគ្លីនិកចំពោះអ្នកផ្ទុកជំងឺដែលមានលក្ខណៈខ្ពស់ (២) ផ្តល់ការព្យាបាលឱ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់នៅគ្រប់ករណីនៃការកើតមានទាំងអស់ (៣) ធ្វើរបាយការណ៍អំពីការកើតមាននិងតាមដានអ្នកដែលប៉ះពាល់ឬនៅជាមួយនឹងអ្នកជំងឺ (៤) ផ្តល់ការណែនាំអំពីការប្រើថ្នាំការពារជំងឺគ្រុនចាញ់អោយបានត្រឹមត្រូវ (៥) ជ្រលក់មុងជាមួយនឹងរបាយ Pyrathroid (៦) អនុវត្តន៍គំរោងកែលំអអនាម័យដើម្បីបំបាត់កន្លែងរស់នៅរបស់មូស និងផ្តល់ការអប់រំអំពីបញ្ហាសុខភាព និងការការពារជំងឺគ្រុនចាញ់ (៧) ដាក់សំណាញ់តាមទ្វារ និងបង្អួចផ្ទះ (៨) ប្រើមុងជាប្រចាំ (៩) ស្លៀកពាក់ខោអាវដៃវែងនិងប្រើថ្នាំការពារមូស (១០) តាមដានគ្លីនិកនិងរោគសញ្ញារបស់ជំងឺ (១១) ធ្វើរោគវិនិច្ឆ័យនិងផ្តល់ការព្យាបាលអោយបានទាន់វេលា និង (១២) ត្រួតពិនិត្យនូវឧប្បត្តិហេតុនិងកំណត់ទីកន្លែងកើតមានជំងឺ។<br>(២) **ការគ្រប់គ្រងការរាគត្បាត:** វិធានការគ្រប់គ្រងការរាគត្បាតមាន (១) បំបែកអ្នកជំងឺអោយនៅដោយឡែក និងព្យាបាលទៅតាមប្រភេទជំងឺ (២) បាញ់ថ្នាំក្នុងបរិវេណរស់នៅ២០០ម៉ែត្រ ដើម្បីសម្លាប់មូសដែលពេញវ័យ (៣) ស្វែងរក និងបំផ្លាញជំរកមូស (៤) ប្រើប្រាស់ថ្នាំសំលាប់ពងមូសតាមកន្លែងមានមូសច្រើន និង (៥) អប់រំបុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការគ្រប់គ្រងការរាគត្បាត។ | វិនិយោគិន | គ្មានព័ត៌មាន |

| សកម្មភាពគំរោង | សក្តានុពលផលប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយផលប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង (ត)** | | | | |
| **ការធ្វើផែនការ** | សុខភាពការងារ និងផែនការសុវត្ថិភាព | (៣) **ការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត:** ការកើតជំងឺគ្រុនពោះវៀន រាគមូល អាសន្នរោគ រលាកថ្លើម និងទឹកស៊ីជើងមានកំរិតខ្ពស់ ដោយសារការខ្វះអនាម័យ ការប្រើប្រាស់បង្គន់សាធារណៈមានកំរិតទាប ការផ្គត់ផ្គង់ទឹកស្អាតនៅមានកំរិត និងការខ្វះអនាម័យរបស់កម្មករ។ អនុសាសន៍មួយចំនួនដែលអនុវត្តសម្រាប់ការពារនូវការកើតនូវជំងឺខាងលើមាន: (ក) ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ (ខ) ត្រួតពិនិត្យជាប្រចាំអំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក) (គ) ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា (ឃ) តាមដានរកប្រភពចំលងនិងផ្តល់ការព្យាបាល (ង) ធានាអោយបាននូវសុវត្ថិភាព និងអនាម័យកាកសំណល់ និងការបោះចោលនូវកាកសំណល់រឹងនៅក្នុងផ្ទះដែលសង់សំរាប់កម្មករ (ច) កែលំអការសម្អាតបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅដោយការសង់បង្គន់អនាម័យ និងកន្លែងចោលកាកសំណល់រឹង (ឆ) កែលំអអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ (ជ) ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម និង (ឈ) រាយការណ៍និងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុរបស់ជំងឺ។ | វិនិយោគិន | គ្មានព័ត៌មាន |

Draft

| សកម្មភាពគំរោង | សក្តានុពលផលប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយផលប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
| --- | --- | --- | --- | --- |
| **មុនពេលប្រតិបត្តិគំរោង (ត)** | | | | |
| **ការធ្វើផែនការ** | សុខភាពការងារ និងផែនការសុវត្ថិភាព | (៤) **ការការពារជំងឺផ្លូវភេទ:** ការការពារជំងឺផ្លូវភេទចំពោះកម្មករ និងសហគមន៍មូលដ្ឋាន អាចធ្វើបានតាមរយៈ (ក) អប់រំបុគ្គលិកកម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀតដូចជា: ការទប់ស្កាត់នូវទំនាក់ទំនងជាមួយអ្នកដែលធ្វើអាជីវកម្មផ្លូវភេទការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺអោយព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង និង (ខ) រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចម្លង និងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាង ភ្នាក់ងារសុខាភិបាល អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។<br><br>(៥) **ការរៀបចំផ្ទះ និងសុខភាព:** ការរៀបចំផ្ទះមិនបានត្រឹមត្រូវ អាចនាំអោយមានការចម្លងប៉ារ៉ាស៊ីត ជំងឺចំលងតាមខ្យល់ គ្រោះថ្នាក់ដោយការប៉ះទង្គិច និងស្រ្តេសជាដើម។ តែបញ្ហាទាំងនេះអាចកាត់បន្ថយតាមរយៈការអនុវត្តន៏វិធានការមួយចំនួនដូចជា: (ក) ត្រូវរៀបចំប្លង់កសាងទីស្នាក់ស្នួលឱ្យបានត្រឹមត្រូវ (ខ) ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមល័ក្ខខ័ណ្ឌ: (គ) ទីតាំងផ្ទះចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពកខ្វក់ និងកន្លែងដែលមានសត្វល្អិតច្រើន។ ផ្ទះត្រូវមានសំណាញ់ការពារមូស មានពន្លឺ និងចរន្តខ្យល់គ្រប់គ្រាន់ (ឃ) លក្ខណ:អនាម័យ: ផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ជាមួយនឹងមធ្យោបាយសំរាប់ដុសលាងនិងងូតទឹក សង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលកាកសំណល់រឹងត្រឹមត្រូវ និង (ង) ពិនិត្យអំពីលទ្ធភាពនៃការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់) និងមណ្ឌលសុខភាព។ | វិនិយោគិន | គ្មានព័ត៌មាន |
| | ហានិភ័យសុវត្ថិភាព | • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងមុនពេលប្រគល់ភារកិច្ចផ្សេងៗ។ | វិនិយោគិន | គ្មានព័ត៌មាន |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង (ត)** | | | | |
| ការដោះស្រាយបញ្ហាកម្មសិទ្ធិដី | លំនាំនៃការផ្លាស់ប្តូរកម្មសិទ្ធិដី | • ការដោះស្រាយបញ្ហាកម្មសិទ្ធិដីត្រូវមានលក្ខណៈគតិយុត្តិ ដោយផ្អែកទៅលើលទ្ធភាពបែការប្រើប្រាស់ដី និងឬទិន្នផលដែលម្ចាស់ដីធ្លាប់ទទួលបានពីមុន ។ | | |
| ការរៀបចំទីតាំងសំរាប់ចតគ្រឿងចក្រ | បង្កការកខ្វក់ដល់មជ្ឈដ្ឋានជុំវិញដោយការលើកដីរៀបចំទីតាំងចតគ្រឿងចក្រ | • ការលើកដីធ្វើជាទីតាំងសម្រាប់ចតគ្រឿងចក្រមានដូចជា ឡានដឹកដី ម៉ាស៊ីនកាយដី ម៉ាស៊ីនពង្រាបដី ម៉ាស៊ីនឈូសដី ម៉ាស៊ីនកិនបង្ហាប់ដី។ល។ គឺត្រូវការទំហំផ្ទៃដីប្រមាណ៦ហិកតា។ ការលើកដីនេះនឹងបង្កអោយកខ្វក់ដល់មជ្ឈដ្ឋានជុំវិញដូចជា: ការករជាកំណរល្បាប់ឬខ្សាច់នៅក្នុងតំបន់និងប្រភពទឹកដែលមាននៅជុំវិញនោះ ។ តែហេតុប៉ះពាល់នេះមិនបង្កជាបញ្ហាធ្ងន់ធ្ងរដល់បរិស្ថានឡើយ ហើយអាចកាត់បន្ថយបានតាម: (១) ការដាំស្មៅនៅជុំវិញបរិវេណ (២) កិនបង្ហាប់ទីតាំងនោះអោយបានហាប់ល្អ និង (៣) ក្រាលគ្រួសក្រហមពីលើអោយបានកំរាស់ពី ១០-១៥ស.ម ហើយកិនបង្ហាប់អោយល្អ ។ | វិនិយោគិន | គ្មានព័ត៌មាន |
| ទីតាំងរោងជាង និងកន្លែងស្តុកប្រេង | | • ប្រភពទឹកដែលមាននៅតាមទីកន្លែងស្តុកប្រេង ឃ្លាំងសម្ភារៈ កន្លែងសាងសង់ងាយនឹងទទួលរងនូវភាពកខ្វក់បំផុតដោយឧប្បត្តិហេតុធ្លុះធ្លាយឬការហូរចេញពីគ្រឿងចក្រ សំភារៈសំណល់ឬក៏ភាពកខ្វក់ដែលកើតឡើងដោយកំលាំងពលកម្ម ដែលអាចបង្កអោយកខ្វក់ដល់ដីនិងទឹក។ អាស្រ័យហេតុនេះប្រេងឥន្ធនៈ និងប្រេងរំអិលផ្សេងៗសំរាប់ការសាងសង់ និងសំភារៈគ្រោះថ្នាក់ដទៃទៀតចាំបាច់ត្រូវរក្សាអោយផុតពីកម្រិតកំពស់ទឹកជំនន់ ហើយនឹងមានចំងាយយ៉ាងតិច៣០-៥០ម៉ែត្រពីប្រភពទឹកដូចជា: ប្រព័ន្ធផ្លូវទឹក ប្រឡាយ និងស្រះទឹកជាដើម ។ កន្លែងស្តុកប្រេងនិងរោងជាងត្រូវសង់អោយខ្ពស់ជាងកំរិតកំពស់ទឹកជំនន់ និងស្ថិតនៅក្នុងកន្លែងមួយដែលមានសុវត្ថិភាព ហើយការពារដោយអាងរក្សាប្រេងបិទជិតមួយដែលមានលទ្ធភាពគ្រប់គ្រាន់អាចស្តុកប្រេង ដែលហូរចេញពីកន្លែងស្តុកប្រេងបាន ។ | | |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការសាងសង់ទីស្នាក់ការស្នូល និងប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន** | | | | |
| **ការឈូសសម្អាតរុក្ខជាតិចេញពីទីតាំងសាងសង់ទីស្នាក់ការស្នូល និង ប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន** | បង្កការក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញដោយសការលើកដីរៀបចំទីតាំងចតគ្រឿងចក្រ | • ដើម្បីសាងសង់ទីស្នាក់ការស្នូល និងប្រព័ន្ធផ្លូវនៅក្នុងតំបន់ដីសម្បទាន ក្រុមហ៊ុនត្រូវឈូសសម្អាតព្រៃចំនួន៣៩៥ហិកតា។ ការឈូសសម្អាតនេះក៏អាចបណ្តាលអោយក្រខ្វក់ដល់ មជ្ឈដ្ឋានជុំវិញដែរ តែដោយសារទីតាំងសាងសង់នោះធំ ហើយរុក្ខជាតិដែលមាននៅលើទីតាំងនោះមានមិនច្រើន ដូច្នេះហេតុប៉ះពាល់នេះគឺមិនធ្ងន់ធ្ងរទេហើយអាចកាត់បន្ថយបានតាមរយៈ (១) ឈូសរុក្ខជាតិដែលមាននៅទីនោះទៅគរទុកអោយមានសណ្តាប់ធ្នាប់ ពេលស្ងួតអាចដុតចោល ឬមួយក៏ប្រគល់អោយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះប្រមូលយកទុកប្រើប្រាស់ជាឧស (២) មិនត្រូវឈូសរុក្ខជាតិទាំងនោះទៅគរទុកលើប្រព័ន្ធផ្លូវទឹក (ប្រឡាយឬអូរ) ដែលអាចបង្កអោយមានការស្ទះដល់ចរន្តទឹកទេ និង (៣) រុក្ខជាតិធំៗ ត្រូវប្រើប្រាស់ទៅតាម លទ្ធភាពដែលអាចប្រើបាន។ | វិនិយោគិន | គ្មានព័ត៌មាន |
| | រំខានដល់មជ្ឈដ្ឋានជុំវិញ (សម្លេង រំញ័រ និងធូលី) | • ផលប៉ះពាល់បណ្តាលមកពីសម្លេង រំញ័រ និងធូលីបង្កដោយការធ្វើចរាចរណ៍របស់គ្រឿងចក្រនិងការបង្កអោយមានធូលី។ ហេតុប៉ះពាល់នេះមិនធ្ងន់ធ្ងរទេ ហើយអាចកាត់បន្ថយបានដោយការផ្តល់ដំណឹងអំពីកាលវិភាគការងារដល់សហគមន៍នៅក្នុងតំបន់នោះ។ បញ្ហាដែលបង្កចំពោះដំណុះរុក្ខជាតិនៅក្នុងតំបន់ អាចអូសបន្លាយរយៈពេល៦ខែរហូតដល់មានភ្លៀង។ ប៉ុន្តែហេតុប៉ះពាល់នេះអាចកាត់បន្ថយបានតាមរយៈការជ្រើមផ្លូវដោយការស្រោចទឹកជាប្រចាំ ហើយម្យ៉ាងទៀតនៅពេលមានភ្លៀងធ្លាក់ ទឹកភ្លៀងនឹងលាងជម្រះធូលីនោះចេញ ហើយរុក្ខជាតិនឹងដុះលូតលាស់ជាធម្មតាវិញ។ | វិនិយោគិន | គ្មានព័ត៌មាន |
| | ការច្រោះដី និងការដុះដី | • ការចាក់ឬលើកដីដើម្បីសាងសង់ទីស្នាក់ការស្នូល ឬប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន ត្រូវផ្អាកនៅពេលមានភ្លៀងធ្លាក់ខ្លាំង ឬធ្វើត្រូវបញ្ចប់មុនពេលរដូវភ្លៀងធ្លាក់ខ្លាំង ដើម្បីជៀសវាងការរំខានឬផលប៉ះពាល់ដែលអាចកើតមានទៅលើដីធ្ងន់ធ្ងរ។ | | |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង – ការធ្វើផ្លូវនៅក្នុងតំបន់សម្បទាន** | | | | |
| ការធ្វើប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន | ការច្រោះដី និងការដុះដី | • វិធានការណ៍មួយចំនួនដែលប្រើសម្រាប់កាត់បន្ថយផលប៉ះពាល់នៅក្នុងពេលធ្វើផ្លូវមាន:<br>✓ រក្សានូវមុំរបស់ផ្លូវ ទៅតាមផែនការវិស្វកម្មព្រៃឈើ ( មិនធំជាង១០ភាគរយចំពោះដីជ្រាយ និង មិនធំជាង១៤ភាគរយចំពោះដីរឹង)<br>✓ ជៀសវាងទីជំរាលវែងដែលជាកន្លែងទឹកហូរចេញពីទ្រូងផ្លូវ ។ នៅកន្លែងដែលទីជំរាលវែង មិនអាចជៀសវាងបាន ត្រូវជីកចង្ហូរកាត់ទីជំរាល ចាក់ដីខ្សាច់ក្រាល និងជីកចង្ហូរនៅតាមដងផ្លូវ<br>✓ ត្រូវកាយចង្ហូរនៅតាមដងផ្លូវ ហើយទ្រូងផ្លូវត្រូវមានរាងជាខ្នងអណ្តើក ដើម្បីអោយងាយហូរធ្លាក់ទៅចង្ហូរ ។<br>✓ ជៀសវាងការដឹកធ្ងន់នៅក្នុងពេលកំពុងភ្លៀងឬនៅក្នុងសណ្ឋានភាពសើម<br>✓ ខ្នងផ្លូវត្រូវក្រាលថ្មបាយក្រៀមឬក៏កំទេចថ្ម<br>✓ ប្រើប្រាស់គ្រឿងចក្រអោយបានសមស្របដើម្បីកាត់បន្ថយផលប៉ះពាល់ពីការដាច់ដី<br>✓ ការពារតំបន់រណបរបស់អូរ និងស្ទឹង: រុក្ខជាតិដែលដុះនៅតាមដងស្ទឹងចាំបាច់ត្រូវរក្សាទុកទាំងស្រុងដើម្បីការពារផ្លូវទឹក និងជីវិតនៅក្នុងទឹក ។ នេះគឺជាវិធានការណ៍មួយដែលមានប្រសិទ្ធិភាពបំផុតក្នុងការកាត់បន្ថយហេតុប៉ះ ពាល់តាមប្រព័ន្ធប្រភពទឹក ។ | | |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង - ការឈូសសំអាតព្រៃដើម្បីដាំដំណាំកសិ-ឧស្សាហកម្ម** | | | | |
| ការឈូសសំអាតព្រៃដើម្បីដាំដំណាំកសិឧស្សាហកម្ម | ការច្រោះដី និងការដុះដី | • វិធានការណ៍មួយចំនួនដែលប្រើសម្រាប់កាត់បន្ថយផលប៉ះពាល់ នៅក្នុងពេលឈូសសំអាតព្រៃដើម្បីដាំដំណាំកសិឧស្សាហកម្មមាន:<br>✓ ឈូសបើកគំរបព្រៃទៅតាមលទ្ធភាពនៃការដាំដុះនៅក្នុងឆ្នាំ ពោលគឺមិនត្រូវបន្សល់នូវផ្ទៃដីដែលឈូសហើយដោយមិនធ្វើការដាំដុះបានទេ។<br>✓ កាកសំណល់ធំៗ របស់ឈើដែលកើតមាននៅក្នុងរយៈពេលនៃការឈូស និងសំបកត្រូវកាត់ជាកំណាត់តូចៗ និងរាយនៅតាមដងផ្លូវ ប៉ុន្តែមិនត្រូវរុញអោយទៅកកស្ទះនឹងរុក្ខជាតិដែលនៅសេសសល់តាមដងផ្លូវឬក៏នៅកន្លែងទីជម្រាលនោះទេ។ ពីព្រោះថា ក្រៅពីការការពារដីកាកសំណល់ទាំងនេះនិងពុកផុយ និងផ្តល់ជីដល់ដីទៀតផង។<br>✓ ដោយសារដំឡូងជាដំណាំដែលមានការដុះលូតលាស់លឿន ដូច្នេះវាអាចដើរតួនាទីជាគំរបដីយ៉ាងល្អក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីមានការដាំដុះ។ | | |
| ប្រតិបត្តិការរៀបចំដី | ការច្រោះដី និងការដុះដី | • ការរៀបចំរណ្តៅលើផ្ទៃដីដែលឈូសហើយ មិនត្រូវប្រើវិធីភ្ជួរទេ ព្រោះការភ្ជួរនេះធ្វើអោយដីបែកខ្ទាំងនេះនឹងបង្ករអោយមានការហូរច្រោះ និងសឹកដាច់មានកំរិតខ្ពស់។<br>• ការប្រើវិធីខួងដីធ្វើរណ្តៅដាំដំណាំ អាចទប់ស្កាត់ការហូរច្រោះនឹងសឹកដាច់បានប្រសើរ ហើយការប្រើវិធីនេះធ្វើអោយអស់សោហ៊ុយតិចហើយលឿនទៀតផង។ | | |
| ប្រតិបត្តិការដាំដុះ | ដាំមិនទាន់ធ្វើអោយដីសល់ទំនេរ | • កំណត់ពេលវេលាដាំដុះអោយបានត្រឹមត្រូវតាមរដូវកាល និងតាមផែនការដែលបានគ្រោងទុក។<br>• រៀបកម្លាំងការងារ (ទាំងមនុស្ស និងគ្រឿងចក្រ) អោយបានត្រឹមត្រូវទៅតាមសមាមាត្រជាមួយនឹងទំហំការងារ។<br>• មុននឹងចាប់ផ្តើមប្រតិបត្តិការ កម្លាំងពលកម្មទាំងអស់ត្រូវបណ្តុះបណ្តាលអោយបានដិតដល់ដោយការសាកល្បងផ្ទាល់លើការងារ ( បទពិសោធន៍ សុខភាព សុវត្ថិភាព និងបញ្ហាបរិស្ថាន ។ | | |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង – ការឈូសសំអាតព្រៃដើម្បីដាំដំណាំកសិ-ឧស្សាហកម្ម (ត)** | | | | |
| សម្លេង | ការរំខានដល់អារម្មណ៍ និងសោតវិញ្ញាណរបស់ពលករ | • កាត់បន្ថយល្បឿនរបស់គ្រឿងចក្រ<br>• ចៀសវាងការធ្វើការនៅពេលយប់<br>• កំណត់ពេលវេលានៃប្រតិបត្តិការទាំងឡាយណាដែលមានសំលេងខ្លាំង<br>• ពិនិត្យ និងតាមដានគ្រឿងចក្រឱ្យបានញឹកញាប់ និងដូរគ្រឿងបំលាស់ថ្មីចំពោះកន្លែងខូចខាតដែលជាមូលហេតុនាំឱ្យមានសំលេងខ្លាំងខុសប្រក្រតី<br>• ត្រូវភ្ជាប់ ឬតំឡើងនូវប្រដាប់ការពារសំលេង<br>• ត្រូវផ្តល់នូវឧបករណ៍ពាក់ត្រចៀកចំពោះអ្នកដែលប្រើរណារអារឈើ ដើម្បីកាត់បន្ថយ គ្រោះនៃការបាត់បង់សមត្ថភាពសោតវិញ្ញាណ | | |
| ការចោលសំណល់រឹងផ្សេងៗទៅក្នុងមជ្ឈដ្ឋានជុំវិញ | ធ្វើអោយក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ | • ចោលកាកសំណល់រឹងទៅក្នុងរណ្តៅជាមួយនឹងការលុបដីជាប្រចាំ ។<br>• ប្រសិនបើអាច ចាំបាច់ត្រូវចោលសំរាមនៅក្រៅកន្លែងរស់នៅ តែប្រសិនបើមិនអាចត្រូវជ្រើសរើសកន្លែងណាមួយនៅក្នុងហើយរៀបចំអោយបានសមស្រប ជៀសវាងការបង្កអោយក្រខ្វក់ដល់ប្រភពទឹក ឬអណ្តូងទឹក ដែលធ្វើអោយបាត់បង់សោភ័ណភាព និងមានក្លិនស្អុយ ។<br>• រៀបចំប្រព័ន្ធលូសំរាប់ស្តុកកាកសំណល់<br>• ហាមចាក់ប្រេង រូបធាតុរំលាយ ឬប្រេងរំអិលទៅលើដី ស្ទឹង និងប្រព័ន្ធរំដោះទឹកនានា ដែលមាននៅក្នុងតំបន់នោះ ។ | | |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង - ការឈូសសំអាតព្រៃដើម្បីដាំដំណាំកសិ-ឧស្សាហកម្ម (ត)** | | | | |
| ការឈូសសំអាតព្រៃ | ការធ្វើអោយក្រខ្វក់ដល់ប្រភពទឹក | • ត្រូវលុបបំបាត់នូវរាល់សកម្មភាពទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក នៅក្នុងរយៈពេលនៃការអនុវត្តន៍គំរោង តាមរយៈការគ្រប់គ្រងអ្នកម៉ៅការនៅក្នុងពេលនៃគំរោង។ ការប្រើប្រាស់នូវគ្រឿងចក្រក៏ដូចជាការដែលឈូសឈើគរួចដែរ ដើម្បីកាត់បន្ថយនូវការបន្ថែមរូបធាតុក្រខ្វក់ ដូចជាការហូររបស់ដីរចេញពីទីតាំងគំនរឈើសំបូរទៅដោយរូបធាតុ ស៊ុលហ្វីត និងដីរដែលនឹងហូរធ្លាក់ទៅក្នុងប្រព័ន្ធស្ទឹង។<br>• ទាមទារឱ្យមាននូវប្រព័ន្ធមួយដែលមានប្រសិទ្ធិភាព សំរាប់គ្រប់គ្រងការហូរច្រោះខ្សាច់នៅក្នុងពេលសាងសង់នៅក្នុងដំណើរការនៃការរៀបចំផែនការដូចជា ការជីកកប់ និងចាក់បំពេញដី ឬក៏ការរៀបចំប្រព័ន្ធភ្លឺដើម្បីទប់ស្កាត់ការហូរច្រោះ និងបំណែករបស់ដី។ ក្រៅពីនេះត្រូវផ្អាកការងារនៅក្នុងរដូវវស្សា ព្រោះថាតំបន់មួយចំនួននឹងកើតមាននូវដំណុះរុក្ខជាតិតាមលក្ខណៈធម្មជាតិជាថ្មីវិញ ។<br>• ចំពោះអណ្តូងទឹកនៅក្នុងទីស្នាក់ការស្នូល ត្រូវជីកកន្លែងមួយឆ្ងាយពីកន្លែងដែលមានមនុស្សកកកុញ និងកន្លែងដែលគេប្រើប្រាស់តាមលទ្ធភាពដែលអាចធ្វើទៅបាន ជាពិសេសត្រូវឆ្ងាយពីលូទឹកស្អុយបង្គន់ និងកន្លែងដែលគេបោះសំរាមចោល ។ | | |

**២១០.** ថវិកាសរុបដែលគ្រោងសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងរយៈពេលនៃការអភិវឌ្ឍន៍ដំណាក់កាលទីមួយមានចំនួនសរុបពី **៦៦៩.៥៥០,00**ដុល្លារ ។ ថវិកា នោះត្រូវប្រើសម្រាប់: (១) ការអនុវត្តន៍នូវផែនការគ្រប់គ្រងបរិស្ថាន (២) កម្មវិធីត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន។ ចំណែកឯថវិកាបំរុងសម្រាប់ការជួសជុល បរិស្ថាននៅក្នុងករណីចាំបាច់ផ្សេងៗ និងថវិកាបំរុងសម្រាប់ឧបត្ថម្ភសមាជិកគ្រួសារប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងបុគ្គលិកកម្មករដែលមានគ្រោះថ្នាក់ដោយចៃដន្យ នៅក្នុងរយៈពេលនៃប្រតិបត្តិការមិនបានដាក់បញ្ចូលទៅក្នុង តារាងតម្លៃប៉ាន់ស្មានសំរាប់ការអនុវត្តន៍ និងតាមដានពិនិត្យវាយតម្លៃនោះទេ។ ប៉ុន្តែ ក្រុមហ៊ុនត្រូវមានថវិកាបំរុងគ្រប់គ្រាន់សំរាប់គំរោងថវិកានេះ នៅក្នុងករណីនៃឧបទ្ទវហេតុដែលអាចកើតមានឡើងជាយថាហេតុ (សូមមើល តារាង ៦-២) ។

**២១១.** បច្ចុប្បន្នម្ចាស់គំរោងបានជួល Green Consultancy Firm ក្នុងការអនុវត្តន៍នូវ EMP ដូចមានកំណត់នៅក្នុងតារាង ៦-១ និង ៦-៣ ដើម្បីធ្វើការត្រួតពិនិត្យតាមដានវាយតម្លៃនូវដំណើរប្រតិបត្តិការ របស់គំរោងនៅក្នុងដំណាក់កាលទី-១ ។ តារាង៦-២ ខាងក្រោមនេះបង្ហាញពីតម្លៃប៉ាន់ស្មាន សម្រាប់ការអនុវត្តន៍នូវ EMP និងការត្រួតពិនិត្យតាមដានវាយតម្លៃនូវដំណើរប្រតិបត្តិការរបស់គំរោង។

**តារាង ៦-២: តម្លៃប៉ាន់ស្មានសម្រាប់ការអនុវត្តន៍ EMP និងការត្រួតពិនិត្យតាមដាន**

| កម្មវិធី | សកម្មភាពដែលត្រូវអនុវត្ត | បរិមាណ | តម្លៃ (ដុល្លា) | |
|---|---|---|---|---|
| | | | ឯកតា | សរុប |
| ការអនុវត្តន៍ផែនការគ្រប់គ្រង | ការរៀបចំទីស្នាក់ការស្នូល ផ្ទះបុគ្គលិក កម្មករ | - | - | ១៨៥.000,00 |
| | ការរៀបចំទីកន្លែងស្តុកប្រេង និងរោងជាង | - | - | ៦៥.000,00 |
| | ការរៀបចំទីកន្លែងចតគ្រឿងចក្រ | - | - | ១២៥.000,00 |
| | ចំណាយអត់គ្រោងទុក | ២៥ភាគរយ | - | ៩.៣៧៥0,00 |
| | **សរុប-១** | | | **៤៦.៨៧៥0,00** |
| ការត្រួតពិនិត្យ | អាជ្ញាធរដោះស្រាយទំនាស់ និងជំលោះដីធ្លី (ដើមគ្រា) | ៣ខែ | | ៩0.000,00 |
| | កំណត់ព្រំប្រទល់ (ELC - Secretariat) ម្តងដើមគ្រា | ១ខែ | | ៦0.000,00 |
| | គណៈកម្មការអន្តរក្រសួង (ក្នុងរយៈពេលគំរោង) | ៣ខែ/ម្តង | ៥000 | ២0.000,00 |
| | Local Environmental Coordinators (0៣នាក់) | ១ខែ/ម្នាក់ | ៣00 | ១0.៨00,00 |
| | ស្ថាប័នត្រួតពិនិត្យឯករាជ្យ (IMO) - អ្នកជំនាញ២-៣នាក់ | ៣ខែ/ម្តង | ៥000 | ២0.000,00 |
| | **សរុប-២** | | | **២00.៨00,00** |

| | | | |
|---|---|---|---|
| Compensation | ផ្ទៃដីពាក់ព័ន្ធជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង |
| PB | ការជួសជុលបរិស្ថានឡើងវិញ | | តាមការជាក់ស្តែង |
| FGP | បុគ្គលិក កម្មករ ឬសមាជិកសហគមន៍ដែលរងគ្រោះ | | តាមការជាក់ស្តែង |
| | **សរុប-៣** | | **តាមការជាក់ស្តែង** |
| | **សរុប ១+២** | | **៦៦៩.៩៥០,០០** |

**២១២.** ដើម្បីធានាបានថាវិនិយោគិន នឹងទទួលបាននូវផ្ទៃដីសរុបចំនួន៩៩៨៥ហិកតា សម្រាប់បែងចែកការប្រើប្រាស់ទៅតាមមុខងារនៃការប្រើប្រាស់ដី ដូចមានកំណត់នៅក្នុងជំពូក៣ ផែនការនៃការប្រើប្រាស់ដីទំហំនិងទីតាំងនិយាមកា មែននោះ ក្រោយពីរាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍អោយក្រុមហ៊ុនធ្វើការវិនិយោគហើយ ក្រុមហ៊ុនគួរត្រូវសហការជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ និងជំលោះដីធ្លី ដើម្បីធ្វើការបញ្ជាក់ថាផ្ទៃដីខាងលើ ពិតជាដីសាធារណៈរបស់រដ្ឋទាំងស្រុងមិនជាប់ជំពាក់ជាមួយនឹងការប្រើប្រាស់ដី ជាពិសេសពីសំណាក់ឈ្មួញកណ្តាលឱកាសនិយមធ្វើពាណិជ្ជកម្មដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ដោយលើកលែងតែម្ចាស់ដើមមួយចំនួនតូចដែលកាន់កាប់នឹងប្រើប្រាស់ដីតំបន់នោះតាំងពីមុនមក ដែលតម្រូវអោយមានការដោះស្រាយតាមបែបគោលនយោបាយ ។

Draft

## តារាង ៦-៣: សង្ខេបអំពីតំរូវការនៃការត្រួតពិនិត្យការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ** | | | | | | |
| • ស្វែងរកអោយបានទាន់ពេលវេលា ដោយតាមដានលក្ខណៈគ្លីនិករបស់អ្នកផ្ទុកជំងឺដែលមានលក្ខណៈខ្ពស់<br>• ផ្តល់ការព្យាបាលអោយបានត្រឹមត្រូវនៅគ្រប់ករណីនៃការកើតមានទាំងអស់<br>• ធ្វើរបាយការណ៍អំពីការកើតមាន និងតាមដានអ្នកដែលប៉ះពាល់ជាមួយនឹងអ្នកជំងឺ<br>• ផ្តល់ការណែនាំអំពីការប្រើថ្នាំការពារជំងឺគ្រុនចាញ់អោយបានត្រឹមត្រូវ<br>• ជ្រលក់មុងជាមួយនឹងរបាយ Pyrathroid<br>• អនុវត្តន៍គំរោងកែលំអអនាម័យ ដើម្បីបំបាត់កន្លែងរស់នៅរបស់មូស និងផ្តល់ការអប់រំអំពីបញ្ហាសុខភាព និងការការពារជំងឺគ្រុនចាញ់<br>• ដាក់សំណាញ់តាមទ្វារ និងបង្អួចផ្ទះ<br>• ប្រើមុងជាប្រចាំ<br>• ស្លៀកពាក់ខោអាវដៃវែង និងប្រើថ្នាំការពារមូស<br>• តាមដានគ្លីនិក និងរោគសញ្ញារបស់ជំងឺ<br>• ធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាល អោយបានទាន់ពេលវេលា<br>• ត្រួតពិនិត្យនូវឧប្បត្តិហេតុ និងកំណត់ទីកន្លែងកើតមានជំងឺ | វិធីសាស្ត្រការពារជំងឺគ្រុនចាញ់ | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាស នៅក្នុងអាយុកាលនៃការសិក្សាស្រាវជ្រាវនេះ | ម្ចាស់ក្រុមហ៊ុន | គ្មានព័ត៌មាន |

Draft

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួនដងនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ (ត)** | | | | | | |
| • ត្រូវបំបែកអ្នកជំងឺអោយនៅកន្លែងផ្សេង និងផ្តល់ការព្យាបាលជាពិសេសទៅតាមយថាប្រភេទនៃជំងឺ ។<br>• បាញ់ថ្នាំក្នុងបរិវេណរស់នៅចំងាយ ២០០ម ដើម្បីសម្លាប់មូសពេញវ័យ ។<br>• ស្វែងរក និងបំផ្លាញទីតាំងជម្រកមូស ។<br>• ចាំបាច់ត្រូវប្រើថ្នាំសំលាប់ពងមូសចំពោះទីកន្លែងដែលមានមូសច្រើន ។<br>• អប់រំដល់បុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការគ្រប់គ្រងការរាគត្បាត ។ | វិធានការគ្រប់គ្រងការរាគត្បាត | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាសនៅក្នុងអាយុកាលនៃការសិក្សាស្រាវជ្រាវនេះ | ម្ចាស់ក្រុមហ៊ុន | គ្មានព័ត៌មាន |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង - ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ (ត)** | | | | | | |
| • ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ ។<br>• ត្រួតពិនិត្យជាប្រចាំ អំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក) ។<br>• ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។<br>• តាមដានរកប្រភពចំលង និងផ្តល់ការព្យាបាល ។<br>• ធានាអោយបាននូវសុវត្ថិភាព និងសម្អាតសំរាម និងការបោះចោលនូវកាកសំណល់រឹងនៅក្នុងផ្ទះដែលសង់សំរាប់កម្មករ ។<br>• កែលំអការសម្អាត បរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅដោយការសង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលកាកសំណល់រឹង ។<br>• កែលំអអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ ។<br>• ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម ។<br>• រាយការណ៍នឹងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុរបស់ជំងឺ ។ | វិធានការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាស នៅក្នុងរយៈកាលនៃការសិក្សាស្រាវជ្រាវនេះ | ម្ចាស់ក្រុមហ៊ុន | គ្មានព័ត៌មាន |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ (ត)** | | | | | | |
| • អប់រំបុគ្គលិក កម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀត ដូចជាការទប់ស្កាត់នូវទំនាក់ទំនង ជាមួយអ្នកដែលធ្វើអាជីវកម្មលើផ្លូវភេទការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺអោយព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង។<br>• រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចំលង និងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារសុខាភិបាល អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។ | វិធានការការពារជំងឺផ្លូវភេទ | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាសនៅក្នុងអាយុកាលនៃការសិក្សាស្រាវជ្រាវនេះ | ម្ចាស់ក្រុមហ៊ុន | គ្មានព័ត៌មាន |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ (ត)** | | | | | | |
| • ក្រុមហ៊ុនត្រូវរៀបចំប្លង់កសាងទីស្នាក់ការស្នូលអោយបានត្រឹមត្រូវ<br>• ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមល័ក្ខខ័ណ្ឌ<br>• លក្ខណៈរូប: ទីតាំងផ្ទះ ចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពកខ្វក់ និងកន្លែងដែលមានសត្វល្អិតច្រើន។ ផ្ទះកម្មករត្រូវមានសំណាញ់ការពារមូសនិងមានឆ្នាំការពារចោរ ហើយត្រូវមានពន្លឺគ្រប់គ្រាន់។ ម្យ៉ាងវិញទៀត ទីតាំងរបស់ផ្ទះ និងបន្ទប់ត្រូវមានចរន្តខ្យល់គ្រប់គ្រាន់ (ផ្ទៃបន្ទប់ត្រូវបើកចំហរយ៉ាងតិច១០ភាគរយ)។<br>• លក្ខណៈអនាម័យ: ផ្តល់ទឹកស្អាតអោយបានគ្រប់គ្រាន់ ជាមួយនឹងមធ្យោបាយសំរាប់ដុសលាងនិងងូតទឹក សង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលកាកសំណល់រឹងត្រឹមត្រូវ។<br>• ពិនិត្យអំពីលទ្ធភាពនៃការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់) និងមណ្ឌលសុខភាព។ | មានសមាហរិណកម្មបរិស្ថាន និងសុខភាព | ការិយាល័យ | មានការរៀបចំត្រឹមត្រូវទៅតាមគោលការណ៍សមាហរិណកម្មបរិស្ថាន និងសុខភាព | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាស នៅក្នុងអាយុកាលនៃការសិក្សាស្រាវជ្រាវនេះ | ម្ចាស់ក្រុមហ៊ុន | គ្មានព័ត៌មាន |
| • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងអស់មុនពេលប្រគល់ភារកិច្ចផ្សេងៗ។ | សុខភាពការងារ និងផែនការសុវត្ថិភាព | ការិយាល័យ | បុគ្គលិកទាំងអស់ទទួលបានការបណ្តុះបណ្តាលពេញលេញ | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាស នៅក្នុងអាយុកាលគំរោង | អ្នកម៉ៅការរៀបចំប្លង់និងសាងសង់ | គ្មានព័ត៌មាន |

Draft

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការដោះស្រាយបញ្ហាកម្មសិទ្ធិដី** | | | | | | |
| • ការដោះស្រាយបញ្ហាកម្មសិទ្ធិដីត្រូវមានលក្ខណៈគតិយុត្តិ ដោយផ្អែកទៅលើលទ្ធភាពនៃការប្រើប្រាស់ដី និងទិន្នផលដែលម្ចាស់ដីធ្លាប់ទទួលបានពីមុន។ | ម្ចាស់ដីពាក់ព័ន្ធបានទទួលការដោះស្រាយ | ទីវាល | ម្ចាស់ដីពាក់ព័ន្ធបានទទួលការដោះស្រាយ | ម្តងមុនពេលអនុវត្តន៍គំរោង | វិនិយោគិន | ? |
| **មុនពេលប្រតិបត្តិគំរោង – ការរៀបចំទីតាំងសំរាប់ចត គ្រឿងចក្រ** | | | | | | |
| • កិនបង្ហាប់ទីតាំង នោះអោយបានហាប់ល្អ និង<br>• ក្រាលគ្រួសក្រហមពីលើអោយបានកំរាស់ពី ១០-១៥ស.ម ហើយកិនបង្ហាប់ឱ្យល្អ។ | ផែនការសាងសង់ | ទីវាល | បង្ការគ្រោះថ្នាក់ដល់មជ្ឈដ្ឋានជុំវិញ ដោយការលើកដីរៀបចំទីតាំងចត គ្រឿងចក្រ | មុន ក្នុងពេល និងក្រោយពេល | ស្ថាប័នជំនាញ | ? |
| **មុនពេលប្រតិបត្តិគំរោង – ទីតាំងរោងជាង និងកន្លែងស្តុកប្រេង** | | | | | | |
| • កន្លែងរក្សាប្រេងឥន្ធនៈ និងប្រេងរំអិលផ្សេងៗសំរាប់ការសាងសង់ និងសំភារៈគ្រោះថ្នាក់ដទៃទៀតចាំបាច់ត្រូវរក្សាអោយផុតពីកម្រិតកំពស់ទឹកជំនន់ ហើយនឹងមានចំងាយយ៉ាងតិច ៣០-៥០ ម៉ែត្រពីប្រភពទឹកដូចជា: ប្រព័ន្ធផ្លូវទឹក ប្រឡាយ និងស្រះទឹកជាដើម។ កន្លែងស្តុកប្រេង និងរោងជាងត្រូវសង់អោយខ្ពស់ជាងកំរិតកំពស់ទឹកជំនន់និងស្ថិតនៅក្នុងកន្លែងមួយដែលមានសុវត្ថិភាព ហើយការពារដោយរោងរក្សាប្រេងបិទជិតមួយដែលមានលទ្ធភាពគ្រប់គ្រាន់អាចស្តុកប្រេង ដែលហូរចេញពីកន្លែងស្តុកប្រេងបាន។ | ផែនការសាងសង់ | ទីវាល | បង្ការគ្រោះថ្នាក់ដល់មជ្ឈដ្ឋានជុំវិញ ដោយការលើកដីរៀបចំទីតាំងចត គ្រឿងចក្រ | បីខែម្តង | ស្ថាប័នជំនាញ | ? |

Draft

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង - ការសាងសង់ទីស្នាក់ការស្នូល និងប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន** | | | | | | |
| • ឈូសរុក្ខជាតិដែលមាននៅទីនោះទៅគរទុកអោយមានសណ្តាប់ធ្នាប់ ពេលស្ងួតអាចដុតចោល ឬមួយក៏ផ្តល់អោយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះប្រមូលយកទុកប្រើប្រាស់ជាឧស<br>• មិនត្រូវឈូសរុក្ខជាតិទាំងនោះទៅគរទុកលើប្រព័ន្ធផ្លូវទឹក (ប្រឡាយឬអូរ) ដែលអាចបង្កអោយមានការស្ទះដល់ចរន្តទឹកទេ និង<br>• រុក្ខជាតិធំៗ ត្រូវប្រើប្រាស់ទៅតាមលទ្ធភាពដែលអាចប្រើបាន ។ | វិធីសាស្ត្រឈូសឆាយ | ទីវាល | បង្កការកខ្វក់ដល់មជ្ឈដ្ឋានជុំវិញដោយសកម្មភាពឈូសឆាយព្រៃ | បីខែម្តង | ស្ថាប័នជំនាញ | ? |
| • កាត់បន្ថយល្បឿនរបស់គ្រឿងចក្រ<br>• ចៀសវាងការធ្វើការនៅពេលយប់<br>• កំណត់ពេលវេលានៃប្រតិបត្តិការទាំងឡាយណាដែលមានសំលេងខ្លាំង<br>• ពិនិត្យ និងតាមដានគ្រឿងចក្រឱ្យបានញឹកញាប់ និងដូរគ្រឿងបន្លាស់ថ្មីចំពោះកន្លែងខូចខាត ដែលជាមូលហេតុនាំឱ្យមានសំលេងខ្លាំងខុសប្រក្រតី<br>• ត្រូវភ្ជាប់ ឬតំឡើងនូវប្រដាប់ការពារសំលេង<br>• ត្រូវផ្តល់នូវឧបករណ៍ពាក់ត្រចៀកចំពោះអ្នកដែលប្រើរណារអារឈើ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ នៃការបាត់បង់សមត្ថភាពសោតវិញ្ញាណ<br>• ស្រោចផ្លូវដោយការស្រោចទឹកជាប្រចាំ | សកម្មភាពគ្រឿងចក្រ | ទីវាល | បង្កការរំខានដល់អារម្មណ៍ ប្រព័ន្ធសោតវិញ្ញាណ និងប្រព័ន្ធដកដង្ហើម និងការលូតលាស់របស់រុក្ខជាតិ | បីខែម្តង | ស្ថាប័នជំនាញ | ? |

Draft

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង - ការសាងសង់ប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន** | | | | | | |
| • រក្សានូវមុំរបស់ផ្លូវ ទៅតាមផែនការវិស្វកម្មព្រៃឈើ (មិនធំជាង១០ភាគរយចំពោះដីប្រាយ និង មិនធំជាង១៤ភាគរយចំពោះដីរឹង)<br>• ជៀសវាងទីជំរាលវែង ដែលជាកន្លែងទឹកហូរចេញពីថ្លូវផ្លូវ ។ នៅកន្លែងដែលទីជំរាលវែងមិនអាចជៀសវាងបាន ត្រូវជីកចង្អូរកាត់ទីជំរាលចាក់ដីខ្សាច់ក្រាលនិងជីកចង្អូរនៅតាមដងផ្លូវ<br>• ត្រូវកាយចង្អូរនៅតាមដងផ្លូវ ហើយថ្លូវផ្លូវត្រូវមានរាងជាខ្នងអណ្តើក ដើម្បីអោយងាយហូរធ្លាក់ទៅចង្អូរ ។<br>• ជៀសវាងការដឹកធុនធ្ងន់នៅក្នុងពេលកំពុងភ្លៀងឬនៅក្នុងស្ថានភាពសើម<br>• ខ្នងផ្លូវត្រូវក្រាលថ្មបាយក្រៀមឬក៏កំទេចថ្ម<br>• ប្រើប្រាស់គ្រឿងចក្រអោយបានសមស្របដើម្បីកាត់បន្ថយផលប៉ះពាល់ពីការដាច់ដី<br>• ការពារតំបន់រណបរបស់អូរ និងស្ទឹង: រុក្ខជាតិដែលដុះនៅតាមដងស្ទឹងចាំបាច់ត្រូវរក្សាទុកទាំងស្រុងដើម្បីការពារផ្លូវទឹក និងជីវិតនៅក្នុងទឹក ។ នេះគឺជាវិធានការណ៍មួយដែល មានប្រសិទ្ធិភាពបំផុតក្នុងការកាត់បន្ថយហេតុប៉ះពាល់តាមប្រព័ន្ធស្ទឹង ។ | ការច្រោះដី និងការដុះដី | ទីរាល | ការច្រោះដី និងការដុះដី | បីខែម្តង | ស្ថាប័នជំនាញ | ? |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង - ការឈូសសំអាតព្រៃដើម្បីដាំដំណាំកសិឧស្សាហកម្ម** | | | | | | |
| • ឈូសបើកគំរបព្រៃទៅតាមលទ្ធភាពនៃការដាំដុះនៅក្នុងឆ្នាំពោលគឺមិន ត្រូវបន្សល់នូវផ្ទៃដី ដែលឈូសហើយដោយមិនធ្វើការដាំដុះបានទេ ។<br>• ឈូសបើកគំរបព្រៃទៅតាមលទ្ធភាពនៃការដាំដុះនៅក្នុងឆ្នាំពោលគឺមិនត្រូវបន្សល់នូវផ្ទៃដី ដែលឈូសហើយដោយមិនធ្វើការដាំដុះបានទេ ។<br>• ដោយសារជំឡូងជាដំណាំដែលមានការដុះលូតលាស់លឿន ដូច្នេះវាអាចជើតួនាទីជាគំរបដី យ៉ាងល្អក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីមានការដាំដុះ ។ | ការច្រោះដី និងការដុះដី | ទីវាល | ការច្រោះដី និងការដុះដី | បីខែម្តង | ស្ថាប័នជំនាញ | ? |
| **ក្នុងពេលប្រតិបត្តិគំរោង - ប្រតិបត្តិការដាំដុះ** | | | | | | |
| • កំណត់ពេលវេលាដាំដុះអោយបានត្រឹមត្រូវតាមរដូវកាល<br>• រៀបកម្លាំងការងារ (ទាំងមនុស្សនិងគ្រឿងចក្រ) អោយបានត្រឹមត្រូវទៅតាមសមាមាត្រជាមួយនឹងទំហំការងារ ។<br>• មុននឹងចាប់ផ្តើមប្រតិបត្តិការ កម្លាំងពលករទាំងអស់ត្រូវបណ្តុះបណ្តាលអោយបានជិតដល់ដោយ ការសាកល្បងផ្ទាល់លើការងារ ( បទពិសោធន៍ សុខភាព សុវត្ថិភាព និងបញ្ហាបរិស្ថាន ។ | ការច្រោះដី និងការដុះដី | ទីវាល | ការច្រោះដី និងការដុះដី | បីខែម្តង | ស្ថាប័នជំនាញ | ? |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង - សម្លេងនិងធូលី** | | | | | | |
| • កាត់បន្ថយល្បឿនរបស់គ្រឿងចក្រ និងជៀសវាងការធ្វើការនៅពេលយប់<br>• កំណត់ពេលវេលានៃប្រតិបត្តិការទាំងឡាយណាដែលមានសំលេងខ្លាំង<br>• ពិនិត្យ និងតាមដានគ្រឿងចក្រឱ្យបានញឹកញាប់ និងដូរគ្រឿងបន្លាស់ថ្មីចំពោះកន្លែងខូចខាត ដែលជាមូលហេតុនាំឱ្យមានសំលេងខ្លាំងខុសប្រក្រតី<br>• ត្រូវភ្ជាប់ឬតំឡើងនូវប្រដាប់ការពារសំលេង<br>• ត្រូវផ្តល់នូវឧបករណ៍ពាក់ត្រចៀកចំពោះអ្នកដែលប្រើរណារអារឈើ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការបាត់បង់សមត្ថភាពសោតវិញ្ញាណ<br>• ជៀសវាងដោយការស្រោចទឹកជាប្រចាំ | សកម្មភាពគ្រឿងចក្រ | ទីវាល | បង្កការរំខានដល់អារម្មណ៍ ប្រព័ន្ធសោតវិញ្ញាណ និងប្រព័ន្ធដកដង្ហើម និងការលូតលាស់របស់រុក្ខជាតិ | បីខែម្តង | ស្ថាប័នជំនាញ | ? |
| **ក្នុងពេលប្រតិបត្តិគំរោង - ការចោលសំណល់រឹងផ្សេងៗទៅក្នុងមជ្ឈដ្ឋានជុំវិញ** | | | | | | |
| • ចោលកាកសំណល់រឹងទៅក្នុងរណ្តៅជាមួយនឹងការលុបដីជាប្រចាំ ។<br>• ប្រសិនបើអាចចាំបាច់ត្រូវចោលសំរាមនៅក្រៅកន្លែងរស់នៅ តែប្រសិនបើមិនអាចត្រូវជ្រើសរើសកន្លែងណាមួយនៅក្នុងហើយរៀបចំអោយបានសមស្រប ជៀសវាងការបង្កអោយកខ្វក់ដល់ប្រភពទឹកឬអណ្តូងទឹក ដែលធ្វើអោយបាត់បង់សោភ័ណភាព និងមានក្លិនស្អុយ ។<br>• រៀបចំលូសំរាប់ស្តុកកាកសំណល់<br>• ហាមចាក់ប្រេង រូបធាតុរំលាយ ឬប្រេងរំអិលទៅលើដី ស្ទឹង និងប្រព័ន្ធរំដោះទឹកនានាដែលមាននៅក្នុងតំបន់នោះ ។ | ធ្វើអោយកខ្វក់ដល់មជ្ឈដ្ឋានជុំវិញ | ទីវាល | សោភ័ណភាពមជ្ឈដ្ឋានជុំវិញ | បីខែម្តង | ស្ថាប័នជំនាញ | ? |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួនដែលការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង - ការរក្សានូវគុណភាពទឹក** | | | | | | |
| • ត្រូវលុបបំបាត់នូវរាល់សកម្មភាពទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក នៅក្នុងរយៈពេលនៃការអនុវត្តន៍គំរោង តាមរយៈការគ្រប់គ្រងអ្នកម៉ៅការនៅក្នុងពេលនៃគំរោង។ ការប្រើប្រាស់នូវគ្រឿងចក្រក៏ដូចជាការដែលឈូសឈើគរបួដេរ ដើម្បីកាត់បន្ថយនូវការបន្ថែមរូបធាតុក្រខ្វក់ ដូចជាការហូររបស់ដីរចេញពីទីតាំងគំនរឈើសំបូរទៅដោយរូបធាតុ ស៊ុលហ្វីត និងដីរ ដែលនឹងហូរធ្លាក់ទៅក្នុងប្រព័ន្ធស្ទឹង។<br>• ទាមទារឱ្យមាននូវប្រព័ន្ធមួយដែលមានប្រសិទ្ធិភាព សំរាប់គ្រប់គ្រងការហូរច្រោះខ្សាច់ នៅក្នុងពេលសាងសង់នៅក្នុងដំណើរការនៃការរៀបចំផែនការដូចជាការជីកកប់ នឹងចាក់បំពេញដីឬមួយក៏ការ រៀបចំប្រព័ន្ធភ្លឺដើម្បីទប់ស្កាត់ការហូរច្រោះ និងបំណែករបស់ដី។ ក្រៅពីនេះត្រូវផ្អាកការងារនៅក្នុងរដូវវស្សា ព្រោះថាតំបន់មួយចំនួននឹងកើតមាននូវដំណុះរុក្ខជាតិតាមលក្ខណៈធម្មជាតិជាថ្មីវិញ។<br>• ចំពោះអណ្តូងទឹកនៅក្នុងទីស្នាក់ការស្នូល ត្រូវជីកនូវកន្លែងមួយឆ្ងាយពីកន្លែងដែលមានមនុស្សកកកុញ និងកន្លែងដែលគេប្រើប្រាស់តាមលទ្ធភាពដែលអាចធ្វើទៅបាន ជាពិសេសត្រូវឆ្ងាយពីលូទឹកស្អុយ បង្គន់ និងកន្លែងដែលគេបោះសំរាមចោល។<br>• ការរៀបចំប្រព័ន្ធភ្លឺឬទំនប់បញ្ចៀសទឹក ចាំបាច់ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាដើម្បីធានាថាមិនបង្ករការខូចខាត ដល់ប្រព័ន្ធអេកូឡូស៊ីឬក៏ផ្លាស់ប្តូរចរន្តទឹករបស់ប្រព័ន្ធស្ទឹង ឬអូរដោយសំណង់ទំនប់នេះ ដែលជាហេតុឧបសគ្គដល់ការឆ្លងកាត់របស់ត្រី ឬសត្វទឹកផ្សេងៗទៀត។ | ការធ្វើអោយក្រខ្វក់ដល់ប្រភពទឹក | ទីវាល | គុណភាពទឹក | បីខែម្តង | ស្ថាប័នជំនាញ | ? |

Draft

**២១៣.** ក្រុមហ៊ុន (HLH Agriculture (CAMBODIA) CO., LTD) មានផែនការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សហគមន៍មូលដ្ឋានដោយធ្វើអោយប្រសើឡើងនូវលទ្ធភាពក្នុងការទទួលបាន នូវសេវាសាធារណៈផ្សេងៗដែលរួមមាន (១) ការផ្តល់ជូននូវអណ្តូងទឹកស្អាតដល់ប្រជាពលរដ្ឋក្នុងសហគមន៍ (២) ក្រុមហ៊ុនមានគំរោងចូលរួមក្នុងការជួសជុលផ្លូវលំជនបទ ដោយមានផែនការក្នុងមួយឆ្នាំយ៉ាងតិចពី ១៥០០-២០០០ម៉ែត្រ/ឆ្នាំ ក្នុងរយៈពេល០៥ឆ្នាំ ដើម្បីជួយសំរួលដល់ការធ្វើដំណើរ និងដឹកជញ្ជូន (៣)គំរោងសាងសង់និងជួសជុលសាលារៀន ក្នុងមូលដ្ឋាន ផ្តល់ឱកាសច្រើនដល់សិស្សានុសិស្សទទួលបានការអប់រំពេញលេញ (៤) គំរោងបង្កើតនូវប៉ុស្តិ៍សុខភាពតាមភូមិនិមួយៗក្នុងគោលបំណងលើកកំពស់សុខភាពប្រជាជន ក្នុងសហគមន៍ទាំងមូល (៥) គំរោងជីស្រះទឹក និងប្រព័ន្ធស្រោចស្រពក្នុងមូលដ្ឋាន ដល់ប្រជាកសិករដើម្បីប្រើប្រាស់ធានាបាននូវទិន្នផលផលិតកម្មកសិកម្មជាអតិបរមា។ ផែនការ អភិវឌ្ឍន៍សហគមន៍ដូចបានលើកឡើងខាងលើមានបញ្ជាក់លំអិតក្នុងតារាង ៦-៤ ខាងក្រោម៖

**តារាង ៦-៤: ផែនការណ៍ចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានរបស់ក្រុមហ៊ុន** HLH Agriculture (CAMBODIA) CO., LTD

| កម្មវិធី | សកម្មភាពដែលត្រូវអនុវត្ត | គំរោងផ្តល់ជូនតាមឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំទី ១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | សរុប |
| ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ | ផ្តល់អណ្តូងទឹកស្អាត (១អណ្តូង/៥គ្រួសារ) ២០អណ្តូង | ២០ | - | - | - | - | ៧០០០ |
| | ជួសជុល និងសាងសង់ផ្លូវលំជនបទក្នុងតំបន់នៃគំរោង១០គ.ម | ២០០០ម. | ២០០០ម. | ២០០០ម. | ២០០០ម. | ២០០០ម. | ៦០០០០ |
| | កសាង និងជួសជុលសាលារៀន | - | - | - | - | - | - |
| | មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព | - | - | - | - | - | - |
| | សាងសង់ប្រព័ន្ធធារាសាស្ត្រ | - | - | - | - | - | - |
| | ការផ្តល់ឱកាសការងារដល់ប្រជាជន | - | - | - | - | - | - |
| | ផ្សេងៗ | - | - | - | - | - | - |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ការស្នើសុំឱ្យក្រុមហ៊ុនចូលរួមអភិវឌ្ឍន៍មូលដ្ឋានឃុំត្រពាំងជោរ** | | | | | | | |
| ផែនការស្នើសុំ | ជួសជុលអភិវឌ្ឍន៍ផ្លូវលំ ក្នុងឃុំ ១០គ.ម(៦០០ដុល្លា/១គ.ម) | - | - | - | - | - | ៦.០០០ |
| | សាងសង់ទំនប់ទឹកសំរាប់ធ្វើស្រែ | - | | - | | | - |
| | ស្នើសុំអណ្តូងទឹក ២០(៣៥០ដុល្លា/អណ្តូង) | - | | | | | ៧.០០០ |
| | ស្នើសុំសាលារៀន២ ខ្នង ( ភូមិតានិល ភូមិក្រាំងចំបក់ ) | - | | - | - | - | ១២.០០០ |
| | ស្នើសុំប្រាក់ឧបត្ថម្ភដល់គ្រូស្ម័គ្រចិត្ត ២នាក់(២៥ដុល្លា/១នាក់/១ខែ | ៦០០ | ៦០០ | ៦០០ | ៦០០ | ៦០០ | ៣.០០០ |
| | សុំឱ្យក្រុមហ៊ុនផ្តល់អាទិភាពការងារដល់យុវជនឃុំត្រពាំងជោរ | - | | - | | | - |
| | ជួយបង្កើតមណ្ឌលសុខភាពឃុំ ៣០.០០០ ដុល្លា | - | | - | | | ៣០.០០០ |
| | សុំឱ្យក្រុមហ៊ុនជួយផ្តល់នូវពូជដំណាំល្អៗដល់ប្រជាជន | - | | - | | | - |
| | សុំឱ្យក្រុមហ៊ុនជួយបណ្តុះបណ្តាលបច្ចេកទេសដល់ប្រជាជន | - | | - | | | - |
| | សរុប...................................................... | | | | | | **៥៨.០០០ USA** |
| **ការស្នើសុំឱ្យក្រុមហ៊ុនចូលរួមអភិវឌ្ឍន៍មូលដ្ឋានឃុំសង្កែសាទប** | | | | | | | |
| | សុំឱ្យក្រុមហ៊ុនជួសជុលផ្លូវលំក្នុងភូមិ តភ្ជាប់ទៅភូមិផ្សេងៗទៀត ចំងាយ ៣ គ.ម | - | - | - | - | - | ១៨.០០០ |
| | ស្នើសុំអណ្តូងទឹក២០ (៣៥០ដុល្លា/អណ្តូង) | - | - | - | - | - | ៧.០០០ |
| | ស្នើសុំសាលារៀន១ខ្នង | - | - | - | - | - | ៦០.០០០ |
| | ស្នើសុំម៉ាស៊ីនភ្លើងដាក់សាលាឃុំ ១គ្រឿង/១៨០០ដុល្លា | - | - | - | - | - | ១.៨០០ |
| | សុំម៉ូតូសំរាប់បំរើការងារក្នុងឃុំ ១គ្រឿង/១៦០០ដុល្លា | - | - | - | - | - | ១.៦០០ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សុំឱ្យក្រុមហ៊ុនផ្តល់អាទិភាពការងារឱ្យអ្នកភូមិក្នុងឃុំសង្កែសាទប | - | - | - | - | - | - |
| | ជួយបង្កើតមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព ៣០.០០០ | - | - | - | - | - | ៣០.០០០ |
| | សុំស្រះទឹក២ ទំហំ៥០ម x ៥០ម ជំរៅ ៤ម (១៥.០០០ដុល្លា/ស្រះ) | - | - | - | - | - | ៣០.០០០ |
| | **សរុប**............................................ | | | | | | **៣៤.៤០០USA** |